**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ៥៦១ ប្រក

# ប្រកាស
# ស្តីពី
# ការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ

*************

## ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានឃើញអនុក្រឹត្យ លេខ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
-តាមសំណើចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥ របស់លោក ស៊ុម ស៊ីថា ប្រធានគណបក្សប្រជាជាតិខ្មែរ អក្សរកាត់( គ.ប.ជ.ខ) ។

## ស ម្រេ ច

ប្រការ១ : ត្រូវបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សប្រជាជាតិខ្មែរ** ដែលមានទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ ៨៩ $E_4$ ផ្លូវលេខ១៣០ ភូមិទី២ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ២ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល និងគណបក្សប្រជាជាតិខ្មែរ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា និងឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០០៥

ស ខេង

**កន្លែងទទួល :**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
-ដូចប្រការ២
"ដើម្បីអនុវត្ត"
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ